# I .ទីស្ដីការគណៈរដ្ឋមន្ត្រី

## ១. អនុក្រឹត្យ

*រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែតុលា ឆ្នាំ១៩៩៤*

**អនុក្រឹត្យលេខ ៥៨ អនក្រ**

**ស្ដីពីការផ្ទេរនាយកដ្ឋានសុរិយោដីនៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់និង**

**នេសាទ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ទីស្ដីការគណៈរដ្ឋមន្ត្រី**

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្ដីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីចុះ ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងតាមសំណូមពរៈចាំបាច់

**សំរេច**

មាត្រា ១ : ផ្ទេរនាយកដ្ឋានសុរិយោដីនៃក្រសួងកសិកម្មរុក្ខាប្រមាញ់និង នេសាទ ទាំងក្របខ័ណ្ឌមន្ត្រីរាជការរួមទាំងចលនវត្ថុ និងអចលនវត្ថុទាំងអស់អោយ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីស្ដីការ គណៈរដ្ឋមន្ត្រី។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុរដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ និង រដ្ឋមន្ត្រីរដ្ឋលេខាធិការ នៃ ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃឡាយ ព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

*រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៥៩ អនក្រ

## ស្តីពីការប្តូរចនាសម្ព័ន្ធរដ្ឋបាល ក្រុងកែប ពីថ្នាក់ស្រុកមកជាថ្នាក់ក្រុង

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

បានឃើញច្បាប់ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩២ និង អនុក្រឹត្យ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩២ នៃអតីតរដ្ឋកម្ពុជាស្តីពីការបង្កើត ក្រុងកែប និងស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ ក្រុងកែប ។

-បានឃើញអនុក្រឹត្យចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីការប្តូរចនាសម្ព័ន្ធរដ្ឋបាល ក្រុងកែប